# CULTURAL EXCHANGES, PROPERTY, AND COOPERATION

## Import Restrictions

**Agreement Between the**

**UNITED STATES OF AMERICA**

**and CAMBODIA**

**Extending and Amending the Memorandum of Understanding of September 12, 2018**

Signed at Phnom Penh August 30, 2023

Entered into force August 30, 2023

NOTE BY THE DEPARTMENT OF STATE

Pursuant to Public Law 89—497, approved July 8, 1966 (80 Stat. 271; 1 U.S.C. 113)—

". . .the Treaties and Other International Acts Series issued under the authority of the Secretary of State shall be competent evidence . . . of the treaties, international agreements other than treaties, and proclamations by the President of such treaties and international agreements other than treaties, as the case may be, therein contained, in all the courts of law and equity and of maritime jurisdiction, and in all the tribunals and public offices of the United States, and of the several States, without any further proof or authentication thereof."

**AGREEMENT**

**BETWEEN**

**THE GOVERNMENT OF THE UNITED STATES OF AMERICA**

**AND**

**THE GOVERNMENT OF THE KINGDOM OF CAMBODIA**

**TO EXTEND AND AMEND THE MEMORANDUM OF UNDERSTANDING BETWEEN THE GOVERNMENT OF THE UNITED STATES OF AMERICA AND THE GOVERNMENT OF THE KINGDOM OF CAMBODIA CONCERNING THE IMPOSITION OF IMPORT RESTRICTIONS ON CATEGORIES OF ARCHAEOLOGICAL MATERIAL OF CAMBODIA**

Pursuant to Article IV of the Memorandum of Understanding between the Government of the United States of America and the Government of the Kingdom of Cambodia concerning the imposition of import restrictions on categories of archaeological material of Cambodia, signed at Phnom Penh September 12, 2018 ("the MOU"), the Government of the United States of America and the Government of the Kingdom of Cambodia ("the Parties") agree to extend the MOU for a five-year period through September 19, 2028.

The Parties also agree to the following amendments:

1. The title of the MOU is changed to read as follows: "Memorandum of Understanding between the Government of the United States of America and the Government of the Kingdom of Cambodia Concerning the Imposition of Import Restrictions on Categories of Archaeological and Ethnological Materials of Cambodia."

2. Paragraph 3 of the preamble is replaced by the following: "Desiring to reduce the incentive for pillage of irreplaceable archaeological and ethnological materials representing Cambodia's rich cultural heritage; and"

3. Article I.1 is replaced by the following: "The Government of the United States of America shall, in accordance with its legislation, including the Convention on Cultural Property Implementation Act, restrict the importation into the United States of certain archaeological material ranging in date from 2500 B.C. through 1750 A.D., which may include categories of stone, metal, ceramics, glass, bone, and wood, and certain ethnological material, dating from 1400 through 1891 A.D., which includes categories of architectural elements, manuscripts, and religious objects, identified in the list to be promulgated by the Government of the United States of America (hereinafter referred to as the Designated List), unless the Government of the Kingdom of Cambodia issues a license which certifies that such exportation was not in violation of its laws."

4. Article II.4 is replaced by the following: "The Government of the Kingdom of Cambodia shall continue to use its best efforts to engage other countries having a significant import trade in archaeological and ethnological materials from Cambodia to deter a serious situation of pillage of cultural property."

5. Article II.5 is replaced by the following: "Each Government shall use best efforts to encourage further interchange of archaeological and ethnological materials for cultural, educational, and scientific purposes, including long-term loans of such material to promote widespread public appreciation of and access to Cambodia's rich cultural heritage."

6. This Agreement shall enter into force on the date of last signature by the Parties.

IN WITNESS WHEREOF, the undersigned, being duly authorized by their respective Governments, have signed the present MOU.

DONE at **Phnom Penh**, this date **30 August 2023**, in duplicate, in the English and Khmer languages, both texts being equally authentic.

| FOR THE GOVERNMENT OF THE UNITED STATES OF AMERICA | FOR THE GOVERNMENT OF THE KINGDOM OF CAMBODIA |
|---|---|
| ------------------------------------ | ------------------------------------ |
| **His Excellency W. Patrick Murphy** | **Her Excellency Dr. PHOEURNG Sackona** |
| **Ambassador Extraordinary and Plenipotentiary of the United States, Cambodia** | **Minister of Culture and Fine Arts** |

## កិច្ចព្រមព្រៀង
## រវាង
## រដ្ឋាភិបាលសហរដ្ឋអាមេរិក
## និង
## រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

## ដើម្បីពន្យារពេល និងធ្វើវិសោធនកម្មលើអនុស្សរណៈនៃការយោគយល់គ្នា រវាងរដ្ឋាភិបាលសហរដ្ឋអាមេរិក និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការដាក់កម្រិតហាមប្រាម នូវការនាំចូលលើប្រភេទនៃវត្ថុបុរាណរបស់ប្រទេសកម្ពុជា

អនុលោមតាមមាត្រា IV នៃអនុស្សរណៈនៃការយោគយល់គ្នា រវាងរដ្ឋាភិបាលសហរដ្ឋអាមេរិក និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការដាក់កម្រិតហាមប្រាមនូវការនាំចូលលើប្រភេទនៃវត្ថុបុរាណរបស់ប្រទេសកម្ពុជា ដែលត្រូវបានចុះហត្ថលេខានៅរាជធានីភ្នំពេញ នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨ ("អនុស្សរណៈនៃការយោគយល់គ្នា") រដ្ឋាភិបាលសហរដ្ឋអាមេរិក និងរាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋភាគី") យល់ព្រមពន្យារអនុស្សរណៈនៃការយោគយល់គ្នាសម្រាប់រយៈពេលប្រាំឆ្នាំ រហូត ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៨។

រដ្ឋភាគីយល់ព្រមផងដែរ ទៅលើការធ្វើវិសោធនកម្មដូចខាងក្រោម៖

១. ចំណងជើងនៃអនុស្សរណៈនៃការយោគយល់គ្នា ត្រូវបានប្តូរដូចតទៅនេះ៖ "អនុស្សរណៈនៃការយោគយល់គ្នា រវាងរដ្ឋាភិបាលសហរដ្ឋអាមេរិក និងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការដាក់កម្រិតហាមប្រាម នូវការនាំចូលលើប្រភេទនៃវត្ថុបុរាណ និងវត្ថុជាតិពន្ធុសាស្ត្ររបស់ប្រទេសកម្ពុជា"។

២. កថាខណ្ឌ ៣ នៃបុព្វកថា ត្រូវជំនួសដូចតទៅនេះ៖ "ក្នុងគោលបំណងកាត់បន្ថយដល់ការជួយជំរុញឲ្យមានការលួចប្លន់ប្រភេទវត្ថុបុរាណ និងវត្ថុជាតិពន្ធុសាស្ត្រមួយចំនួន ដែលតំណាងឲ្យកេរដំណែលវប្បធម៌ដ៏មានតម្លៃ និងសម្បូរបែបរបស់ប្រទេសកម្ពុជា ដែលមិនអាចរកអ្វីជំនួសបាន និង"

៣. មាត្រា ១.១ ត្រូវជំនួសដូចតទៅ៖ "ដោយអនុលោមទៅតាមច្បាប់របស់ខ្លួន រួមមានអនុសញ្ញាស្តីពី ច្បាប់អនុវត្តន៍លើវិស័យសម្បត្តិវប្បធម៌ រដ្ឋាភិបាលសហរដ្ឋអាមេរិកនឹងដាក់កម្រិតហាមប្រាមលើការនាំចូលមកក្នុងសហរដ្ឋអាមេរិក នូវប្រភេទវត្ថុបុរាណមួយចំនួន គិតចាប់ពីឆ្នាំ ២៥០០ មុនគ្រិស្តសករាជ រហូតដល់ឆ្នាំ ១៧៥០ នៃគ្រិស្តសករាជ ដែលអាចរួមមានប្រភេទនៃថ្ម លោហធាតុ កុលាភាជន៍ កែវ ឆ្អឹង និងឈើ និងវត្ថុជាតិពន្ធុសាស្ត្រមួយចំនួន គិតចាប់ពីឆ្នាំ ១៤០០ ដល់ឆ្នាំ ១៨៩១ នៃគ្រិស្តសករាជ ដែលអាចរួមមានប្រភេទនៃគ្រឿងបង្គុំស្ថាបត្យកម្ម សាស្ត្រាស្លឹករឹត និង

គ្រឿងរណ្តាប់សាសនា ដែលបានបញ្ជាក់កិនភាគក្នុងបញ្ជីដែលរដ្ឋាភិបាលសហរដ្ឋអាមេរិក នឹងប្រកាសផ្សាយជាសាធារណៈ (ក្រោយមកនឹងនិយាយយោងទៅលើបញ្ជីកំណត់ទុកជាមុន) វៀរលែងតែរាជរដ្ឋាភិបាលកម្ពុជាចេញអាជ្ញាប័ណ្ណមួយ ដែលបញ្ជាក់ថាការនាំចេញនេះមិនរំលោភលើច្បាប់របស់ខ្លួន។

៤. មាត្រា ២.៤ ត្រូវជំនួសដូចតទៅនេះ៖ "រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួននៅក្នុងការធ្វើកិច្ចសហការជាមួយប្រទេសដទៃ ដែលមានការជួញដូរនាំចូលច្រើននូវវត្ថុបុរាណ និងវត្ថុជាតិពន្ធុសាស្ត្រពីប្រទេសកម្ពុជា ដើម្បីឲ្យបន្ធូរស្ថានភាពធ្ងន់ធ្ងរនៃការលួចប្លន់សម្បត្តិវប្បធម៌" ។

៥. មាត្រា ២.៥ ត្រូវជំនួសដូចតទៅ៖ "រដ្ឋាភិបាលនីមួយៗ ត្រូវធ្វើកិច្ចខិតខំប្រឹងប្រែងដ៏ប្រសើរបំផុត ដើម្បីលើកទឹកចិត្តឲ្យមានបំលាស់ប្តូរវត្ថុបុរាណ និងវត្ថុជាតិពន្ធុសាស្ត្រ ក្នុងគោលបំណងវប្បធម៌ អប់រំ និងវិទ្យាសាស្ត្រ រួមមានកម្ចីនៃវត្ថុបុរាណ និងវត្ថុជាតិពន្ធុសាស្ត្រទាំងនេះសម្រាប់រយៈពេលយូរ ដើម្បីបើកឱកាសឲ្យសាធារណជនជាទូទៅបានចូលមើល និងយល់ដឹងអំពីកេរដំណែលវប្បធម៌ដ៏មានតម្លៃរបស់ប្រទេសកម្ពុជា"។

៦. កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាន នៅថ្ងៃចុះហត្ថលេខាចុងក្រោយដោយរដ្ឋភាគី។

ជាកសិណសាក្សី ហត្ថលេខាខាងក្រោមនេះ ដែលត្រូវបានអនុញ្ញាតធ្វើជាតំណាងរដ្ឋាភិបាលនីមួយៗ បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នានេះ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣, ចំនួនពីរច្បាប់, ជាភាសាអង់គ្លេស និងខ្មែរ។ ឯកសារទាំងពីរមានអត្ថន័យត្រឹមត្រូវដូចគ្នា។

**តំណាងរដ្ឋាភិបាល**
**សហរដ្ឋអាមេរិក**

---------------------------------

**ឯកឧត្តម** W. Patrick Murphy **ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសហរដ្ឋអាមេរិក ប្រចាំកម្ពុជា**

**តំណាងរដ្ឋាភិបាល**
**នៃព្រះរាជាណាចក្រកម្ពុជា**

---------------------------------

**លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា**
**រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**